## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្ដីព្រាង

# ច្បាប់

# ស្ដីពី

# លទ្ធកម្មសាធារណៈ

រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ច្បាប់នេះ មានគោលបំណងធានាឱ្យដំណើរការលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល និងការជួលសេវាកម្ម និងសេវាទីប្រឹក្សា ប្រព្រឹត្តទៅប្រកបដោយតម្លាភាព គណនេយ្យភាព ភាពយុត្តិធម៌ ប្រសិទ្ធភាព ការសន្សំសំចៃ និងទាន់ពេលវេលា ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធលទ្ធកម្មសាធារណៈឯកភាពមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២._**

ច្បាប់នេះ មានគោលដៅកំណត់អំពីវិធីសាស្ត្រ នីតិវិធី វិធាន និងបទប្បញ្ញត្តិ និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រង និងអនុវត្តគ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣._**

ច្បាប់នេះ មានវិសាលភាពគ្របដណ្តប់គ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីប្រភពធនធាន លើកលែងតែ :

- កិច្ចលទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដែលត្រូវអនុវត្តតាមគោលការណ៍ណែនាំ និងនីតិវិធីដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីគោលការណ៍ណែនាំ និងនីតិវិធីលទ្ធកម្មណាមួយផ្សេងទេ ដំណើរការលទ្ធកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

- កិច្ចលទ្ធកម្មដែលប៉ះពាល់ស្រួចស្រាល់ដល់នយោបាយ មានឥទ្ធិពលខ្លាំងដល់ការសម្ងាត់វិស័យការពារជាតិ និងសន្តិសុខសាធារណៈ ហើយដែលត្រូវមានការសម្រេចពីគណៈរដ្ឋមន្ត្រី ឬ នាយករដ្ឋមន្ត្រី។

- ការលក់ ការជួល ការផ្ទេរ និងការចាត់ចែងដទៃទៀតលើទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការផ្តល់សម្បទានផ្សេងៗរបស់រដ្ឋដែលត្រូវអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដោយឡែក ។

**មាត្រា ៤._**

វាក្យសព្ទបច្ចេកទេសក្នុងច្បាប់នេះមានន័យដូចតទៅ :

- **លទ្ធកម្ម:** សំដៅដល់ការទិញ ឬការរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា តាមរយៈវិធីសាស្ត្រដែលមានចែងក្នុងច្បាប់នេះ។
- **កិច្ចលទ្ធកម្ម:** សំដៅដល់ដំណើរការលទ្ធកម្មចាប់ពីការរៀបចំឯកសារដេញថ្លៃ រហូតដល់ពេលទទួលបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា ។

- **លទ្ធកម្មសាធារណៈ:** សំដៅដល់កិច្ចលទ្ធកម្មដែលធ្វើឡើងដោយក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជន-សាធារណៈ ។
- **ស្ថាប័នអនុវត្តលទ្ធកម្ម:** សំដៅដល់ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ-សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត និងដៃគូឯកជន-សាធារណៈ ដែលអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។
- **ដៃគូឯកជន-សាធារណៈ:** សំដៅដល់ក្រុមហ៊ុនឯកជនដែលទទួលសិទ្ធិ បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិពេញលេញដើម្បីធ្វើហិរញ្ញប្បទានលើគម្រោងផ្សេងៗ ពាក់ព័ន្ធនឹងការសាងសង់ ផ្គត់ផ្គង់ទំនិញ សេវា ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។
- **គណៈកម្មាធិការលទ្ធកម្ម:** សំដៅដល់ក្រុមការងារតែងតាំងដោយប្រធានស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់ទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្ម និងឯកសារដេញថ្លៃ ធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា គ្រប់គ្រងការអនុវត្តកិច្ចសន្យា និង ដោះស្រាយ បណ្តឹងតវ៉ាលទ្ធកម្ម ។
- **សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម:** សំដៅដល់ប្រធាន អនុប្រធាន និង សមាជិកទាំងអស់នៃគណៈកម្មាធិការលទ្ធកម្មដែលបានតែងតាំងដោយប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ។
- **អង្គភាពលទ្ធកម្ម:** សំដៅដល់អង្គភាពមួយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈ និង ជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្មលើការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ។
- **អង្គភាពថវិកា:** សំដៅដល់អង្គភាពមានសមត្ថភាពក្នុងការទទួលខុសត្រូវ និងមានភាពជាម្ចាស់ក្នុងការអនុវត្តសកម្មភាពការងារក្នុងការរៀបចំ និងគ្រប់គ្រងថវិកា ព្រមទាំងក្នុងការត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងការអនុវត្តថវិកាដោយខ្លួនឯង ស្របតាមគោលការណ៍ និងនីតិវិធីរបស់ក្រសួងស្ថាប័ន ។
- **មន្ត្រីលទ្ធកម្ម:** សំដៅដល់ប្រធាន អនុប្រធាន និងមន្ត្រីទាំងអស់របស់អង្គភាពលទ្ធកម្ម នៃស្ថាប័នអនុវត្តលទ្ធកម្ម ។
- **ការដេញថ្លៃ:** សំដៅដល់ដំណើរការលទ្ធកម្មដែលសំណើដេញថ្លៃត្រូវបានដាក់ ទទួល និងវាយតម្លៃ សម្រាប់គោលបំណងប្រគល់កិច្ចសន្យា ។
- **ឯកសារដេញថ្លៃ:** សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្មបានរៀបចំ និងផ្តល់ជាដំបូងទៅឱ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណើដេញថ្លៃ ដែលរួមមានពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញចូលរួមដេញថ្លៃ ឬការស្នើឱ្យដាក់សំណើ សេចក្តីអញ្ជើញចូលរួមក្នុងការកំណត់បុរេលក្ខណសម្បត្តិ សេចក្តី

ណែនាំចំពោះអ្នកដេញថ្លៃ លម្អិតលក្ខណៈបច្ចេកទេស ទំហំការងារ លក្ខខណ្ឌយោង និងលក្ខខណ្ឌនៃកិច្ចសន្យា។

- **សំណើដេញថ្លៃ:** សំដៅដល់សំណុំឯកសាររួមមាន ឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃ និងឯកសារភ្ជាប់មួយចំនួនទៀតដូចមានតម្រូវក្នុងឯកសារដេញថ្លៃ និងបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្ម សម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្ម ឬសេវាទីប្រឹក្សា។
- **ទំនិញ:** សំដៅដល់វត្ថុរាវ រឹង ឬ ជាឧស្ម័ន ដែលមានតម្លៃ ឬ ផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈ បរិក្ខារ គ្រឿងឧបភោគ បរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផងដែរ។
- **សំណង់:** សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធដល់ការងារសាងសង់ ការជួសជុល ការធ្វើឡើងជាថ្មី ការតម្លើង ការជីក ការបូម និងការងារប្រហាក់ប្រហែលដែលបង្កើតឱ្យមានការប្រើប្រាស់កំលាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខារ និង បច្ចេកវិទ្យា ។
- **សេវាកម្ម:** សំដៅដល់សកម្មភាពដែលពាក់ព័ន្ធដល់ការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខារ ឬ បច្ចេកវិទ្យា ដែលនាំមកនូវផលប្រយោជន៍ដល់ស្ថាប័នសាធារណៈ ប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និង សេវាទីប្រឹក្សាទេ។
- **អ្នកដេញថ្លៃ:** សំដៅដល់ឯកត្តបុគ្គល ក្រុមហ៊ុន ឬ ទីប្រឹក្សាដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ និងបានដាក់សំណើដេញថ្លៃ ឬសំណើបញ្ជាក់ពីចំណាប់អារម្មណ៍។
- **សេវាទីប្រឹក្សា:** សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សាឯកត្តជន ដែលពាក់ព័ន្ធនឹងគម្រោងណាមួយ ឬ សម្រាប់ការពង្រឹងពង្រីកស្ថាប័ន ឬបង្កើនសមត្ថភាព។
- **ទីប្រឹក្សា:** សំដៅដល់ក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សាឯកត្តជនដែលមានមុខរបរផ្តល់នូវសេវាផ្នែកបញ្ញា។
- **អ្នកផ្គត់ផ្គង់:** សំដៅដល់ឯកត្តបុគ្គល ឬ ក្រុមហ៊ុនដែលចុះកិច្ចសន្យាលក់ទំនិញជាមួយស្ថាប័នអនុវត្តលទ្ធកម្ម។
- **អ្នកទទួលការ:** សំដៅដល់ឯកត្តបុគ្គល ក្រុមហ៊ុន ឬទីប្រឹក្សា ដែលចុះកិច្ចសន្យាលើការងារសាងសង់ ជួសជុល សេវាកម្ម ឬសេវាទីប្រឹក្សាជាមួយស្ថាប័នអនុវត្តលទ្ធកម្ម ។
- **មុខសញ្ញាលទ្ធកម្ម:** សំដៅដល់មុខទំនិញ សំណង់ សេវាកម្ម ឬ សេវាទីប្រឹក្សា ដែលជាកម្មវត្ថុនៃការដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬការចរចាថ្លៃ ។
- **កញ្ចប់លទ្ធកម្ម:** សំដៅដល់ការប្រមូលផ្តុំមុខសញ្ញាលទ្ធកម្មដែលមានប្រភេទដូចគ្នា លក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នា បញ្ចូលក្នុងក្រុមតែមួយសម្រាប់ធ្វើលទ្ធកម្មតែមួយលើក ។
- **កិច្ចសន្យា:** សំដៅដល់កិច្ចព្រមព្រៀងរវាងស្ថាប័នអនុវត្តលទ្ធកម្មជាមួយអ្នកផ្គត់ផ្គង់ដើម្បីផ្តល់ទំនិញ ឬ រវាងស្ថាប័នអនុវត្តលទ្ធកម្មជាមួយអ្នកទទួលការដើម្បីអនុវត្តការងារសាងសង់ ជួសជុល សេវាកម្ម ឬ ផ្តល់សេវាទីប្រឹក្សា។
- **ការសន្សំសំចៃ:** សំដៅដល់ការសម្រេចបាននូវតម្លៃល្អបំផុតឆ្លងតាមរយៈការប្រកួតប្រជែងដោយយុត្តិធម៌ ។

- **តម្លាភាព:** សំដៅដល់ការបំពេញករណីយកិច្ចឱ្យបានត្រឹមត្រូវ និង ស្មោះត្រង់ក្នុងដំណើរការអនុវត្តកិច្ចលទ្ធកម្ម ។
- **គណនេយ្យភាព:** សំដៅដល់ការធានាឱ្យមានការទទួលខុសត្រូវទាំងឡាយណា ដែលជាប់ពាក់ព័ន្ធជាមួយនឹងដំណើរការអនុវត្តកិច្ចលទ្ធកម្ម ។
- **ប្រសិទ្ធភាព:** សំដៅដល់ដំណើរការនៃកិច្ចលទ្ធកម្មទំនិញ សំណង់ សេវាកម្ម ឬ សេវាទីប្រឹក្សា ដែលត្រូវប្រព្រឹត្តទៅក្នុងភាពរលូនតាមវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈ ហើយឆ្លើយតបពេញលេញតាមតម្រូវការនូវលក្ខណៈបច្ចេកទេស បរិមាណ គុណភាព ពេលវេលា សេវា និងតម្លៃ ។
- **ក្រមសីលធម៌វិជ្ជាជីវៈ:** សំដៅដល់ក្រមដែលអ្នកចូលរួមពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ ត្រូវយល់ដឹង និងអនុវត្តដោយស្មោះត្រង់តាមបទប្បញ្ញត្តិគតិយុត្តជាធរមាន និងអនុវត្តឱ្យបានត្រឹមត្រូវតាមតួនាទី និងមុខងាររបស់ខ្លួន ។
- **សវនកម្ម:** សំដៅដល់ការត្រួតពិនិត្យជាទៀងទាត់រៀងរាល់ឆ្នាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើគ្រប់កិច្ចលទ្ធកម្មដែលបានអនុវត្តរួច និងស្ថិតក្រោមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។
- **បញ្ជីខ្មៅ:** សំដៅដល់បញ្ជីហាមឃាត់ការចូលរួមរបស់អ្នកដេញថ្លៃក្នុងដំណើរការលទ្ធកម្មសាធារណៈ ។
- **អំពើពុករលួយ:** សំដៅដល់ការផ្តល់ ឬការទទួលវត្ថុមានតម្លៃ ដោយផ្ទាល់ ឬ ដោយប្រយោលដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពមិនប្រក្រតីរបស់ភាគីមួយទៀតនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ។
- **អំពើបន្លំ:** សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ ។
- **អំពើឃុបឃិត:** សំដៅដល់ផែនការ ឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរ ឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬ ធ្វើឱ្យមានឥទ្ធិពលទៅលើសកម្មភាពរបស់ភាគីណាមួយក្នុងដំណើរការលទ្ធកម្មសាធារណៈ ឬជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។
- **អំពើបង្ខិតបង្ខំ:** សំដៅដល់ការហាមឃាត់ ឬការគំរាមកំហែងដោយផ្ទាល់ ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិរបស់បុគ្គលដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះ ឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។
- **វិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ:** សំដៅដល់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដែលចេញដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ២
## ស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ

**មាត្រា ៥.–**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាស្ថាប័នគ្រប់គ្រងលទ្ធកម្មសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិអំណាច និងការទទួលខុសត្រូវលើការរៀបចំគោលនយោបាយលទ្ធកម្មសាធារណៈ ការបង្កើត ការកែសម្រួល និងការបំពេញបន្ថែមលើវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិអំណាចពិនិត្យនិងអនុម័តផែនការលទ្ធកម្ម កំណត់កម្រិតទឹកប្រាក់សម្រាប់អនុវត្តគ្រប់វិធីសាស្ត្រលទ្ធកម្ម និងសម្រាប់ផ្តល់ ឬដកសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ត្រួតពិនិត្យឡើងវិញរាល់កិច្ចលទ្ធកម្មដែលមិនទាន់បានផ្តល់សិទ្ធិសម្រេចជូនស្ថាប័នអនុវត្តលទ្ធកម្ម ដោះស្រាយជម្លោះ និងបណ្តឹងតវ៉ាលទ្ធកម្ម ចុះបញ្ជីអ្នកដេញថ្លៃ ចុះបញ្ជីខ្មៅអ្នក ដេញថ្លៃ និងធ្វើសវនកម្មកិច្ចលទ្ធកម្ម ព្រមទាំងអនុវត្តសិទ្ធិអំណាចដទៃទៀតតាមការចាំបាច់ ដើម្បីធានាឱ្យការអនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅបានរលូន និងត្រឹមត្រូវតាមបទប្បញ្ញត្តិនៅក្នុងច្បាប់នេះ។

**មាត្រា ៦.–**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈធ្វើជាសេនាធិការ ក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តលទ្ធកម្ម

**មាត្រា ៧.–**

ប្រធានស្ថាប័នអនុវត្តលទ្ធកម្មត្រូវគ្រប់គ្រង និងដឹកនាំការអនុវត្តកិច្ចលទ្ធកម្មសាធារណៈឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៅក្នុងច្បាប់នេះ អនុក្រឹត្យ វិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

**មាត្រា ៨.–**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្មត្រូវបង្កើតគណៈកម្មាធិការលទ្ធកម្មមួយ ដើម្បីទទួលខុសត្រូវត្រួតពិនិត្យលើផែនការលទ្ធកម្ម និងឯកសារដេញថ្លៃ ធ្វើការវាយតម្លៃប្រគល់កិច្ចសន្យា គ្រប់គ្រងការអនុវត្តកិច្ចសន្យា និង ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មតាមសមត្ថកិច្ចរបស់ខ្លួន។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ជាប្រធានគណៈកម្មាធិការលទ្ធកម្ម។

**មាត្រា ៩.-**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវមានអង្គភាពលទ្ធកម្មមួយដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានមន្ត្រីមានសមត្ថភាពជំនាញផ្នែកលទ្ធកម្មសាធារណៈគ្រប់គ្រាន់ ព្រមទាំងមានសិទ្ធិអំណាចសមស្រប ដើម្បីទទួលខុសត្រូវអនុវត្តរាល់កិច្ចលទ្ធកម្មសាធារណៈ ។ ករណីមានការកែទម្រង់ដែលសម្រេចដោយរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិតម្រូវឱ្យស្ថាប័នអនុវត្តលទ្ធកម្មផ្ទេរសិទ្ធិអំណាចក្នុងការអនុវត្តកិច្ចលទ្ធកម្ម ក្នុងកម្រិតណាមួយទៅឱ្យអង្គភាពថវិកា។ ករណីមានការកែទម្រង់ដែលសម្រេចដោយរាជរដ្ឋាភិបាល អង្គភាពថវិកានៃស្ថាប័នអនុវត្តលទ្ធកម្មអាចអនុវត្តកិច្ចលទ្ធកម្មដោយខ្លួនឯងក្នុងកម្រិតណាមួយ តែត្រូវមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាមី ។

អង្គភាពលទ្ធកម្មមានរចនាសម្ព័ន្ធ ស្ថិតក្រោមប្រធានស្ថាប័នផ្ទាល់ និង ជាសេនាធិការឱ្យគណៈកម្មាធិការលទ្ធកម្ម ។ អង្គភាពលទ្ធកម្មត្រូវដឹកនាំដោយប្រធានមួយរូបដែលមិនត្រូវមានតួនាទី និងភារកិច្ចពាក់ព័ន្ធនឹងកិច្ចការហិរញ្ញវត្ថុផ្សេងទៀតក្នុងស្ថាប័នរបស់ខ្លួនឡើយ ។ ប្រធានអង្គភាពលទ្ធកម្មជាលេខាធិការរបស់គណៈកម្មាធិការលទ្ធកម្ម ។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃអង្គភាពលទ្ធកម្ម និង នីតិវិធីនៃការតែងតាំង ឬ ផ្លាស់ប្តូរប្រធាន និងអនុប្រធានអង្គភាពលទ្ធកម្មត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១០.-**

សមាជិករបស់គណៈកម្មាធិការលទ្ធកម្ម ត្រូវតែងតាំងដោយប្រធានស្ថាប័ន។ សមាជិករបស់គណៈកម្មាធិការលទ្ធកម្មត្រូវមានចំនួនសមស្រប ដែលក្នុងនោះត្រូវមានយ៉ាងហោចណាស់សមាជិកម្នាក់មានជំនាញហិរញ្ញវត្ថុ និងសមាជិកម្នាក់ទៀតមានជំនាញផ្នែកបច្ចេកទេស។ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានសិទ្ធិចាត់តាំងសមាជិកបណ្តោះអាសន្នសម្រាប់អនុវត្តលទ្ធកម្មពិសេសណាមួយដែលត្រូវការចាំបាច់នូវជំនាញ និងចំណេះដឹងពិសេស។ សមាជិកបណ្តោះអាសន្នត្រូវរំសាយដោយស្វ័យប្រវត្តិក្រោយកិច្ចលទ្ធកម្មពិសេសបានបញ្ចប់ ។

អាណត្តិ សមាសភាព និងចំនួននៃសមាជិកគណៈកម្មាធិការលទ្ធកម្មត្រូវកំណត់ក្នុងអនុក្រឹត្យ ។

## ជំពូកទី ៤
## វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និង សេវាកម្ម

**មាត្រា ១១.-**

វិធីសាស្ត្រលទ្ធកម្មទំនិញ សំណង់ និង សេវាកម្ម ត្រូវបានកំណត់ក្នុងមាត្រា១២ មាត្រា១៣ និងមាត្រា១៤ នៃច្បាប់នេះ ។ ការអនុវត្តកិច្ចលទ្ធកម្មត្រូវធ្វើឡើងឱ្យស្របតាមវិធីសាស្ត្រលទ្ធកម្មដែលបានកំណត់ក្នុងផែនការលទ្ធកម្ម លើកលែងតែកាលៈទេសៈពិសេសខ្លះ អាចអនុញ្ញាតឱ្យប្រើវិធីសាស្ត្រផ្សេង ប៉ុន្តែត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន ។ លក្ខខណ្ឌ កម្រិតទឹកប្រាក់ និងនីតិវិធីសម្រាប់អនុវត្តវិធីសាស្ត្រលទ្ធកម្មនីមួយៗ មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ១២.-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយបើកចំហចំពោះគ្រប់អ្នកដេញថ្លៃជាតិ និងអន្តរជាតិ ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ ជាវិធីសាស្ត្រលទ្ធកម្មដែលមានកម្រិតតម្លាភាពខ្ពស់ និងត្រូវបានជំរុញឱ្យប្រើក្នុងកិច្ចលទ្ធកម្មសាធារណៈ ។ វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ រួមមានៈ

ក. ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិៈ វិធីសាស្ត្រនេះត្រូវបានប្រើសម្រាប់គម្រោងលទ្ធកម្មដែលមានទឹកប្រាក់កម្រិតធំ និងមានលក្ខណៈបច្ចេកទេសខ្ពស់ ។

ខ. ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុកៈ វិធីសាស្ត្រនេះត្រូវបានប្រើក្នុងករណីដែលមានផលិតផល មានផលិតកម្ម ឬ មានសម្ថភាពសាងសង់ក្នុងស្រុកគ្រប់គ្រាន់ ។

**មាត្រា ១៣.-**

វិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងដទៃទៀត ជាវិធីសាស្ត្រលទ្ធកម្មដែលមិនមែនជាការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ រួមមានៈ

**ក. ការដេញថ្លៃមានកម្រិតៈ** ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្មដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មគន្លឹះមានលក្ខណៈបច្ចេកទេសស្មុគស្មាញមិនអាចរៀបចំបច្ចេកទេសទុកជាមុន និងមានអ្នកដេញថ្លៃតិចតួចមានសមត្ថភាព ។ វិធីសាស្ត្រនេះតម្រូវឱ្យមានការធ្វើបុរេលក្ខណសម្បត្តិ ។

**ខ. ការពិគ្រោះថ្លៃៈ** ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើសម្រាប់មុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុក និងមានទឹកប្រាក់មធ្យម ។

**គ. ការស្ទង់តម្លៃៈ** ជាវិធីសាស្ត្រលទ្ធកម្មសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដែលត្រូវបានប្រើនៅពេលមុខសញ្ញាលទ្ធកម្មមានរួចជាស្រេចនៅលើទីផ្សារក្នុងស្រុក និងមានទឹកប្រាក់ទាប ។

**មាត្រា ១៤.-**

វិធីសាស្ត្រលទ្ធកម្មដោយឡែក ត្រូវបានប្រើសម្រាប់ជ្រើសរើសអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ដោយមិនមានការដេញថ្លៃ ។ វិធីសាស្ត្រនេះអាចអនុវត្តបានលុះត្រាតែមានការអនុញ្ញាតជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ វិធីសាស្ត្រលទ្ធកម្មដោយឡែក រួមមានៈ

**ក. ការចុះកិច្ចសន្យាផ្ទាល់ៈ** ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឱ្យចរចាថ្លៃ និង បច្ចេកទេសផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ក្នុងកាលៈទេសៈៈ

- មុខសញ្ញាលទ្ធកម្មមានប្រភពតែមួយ

- មុខសញ្ញាលទ្ធកម្មដែលបានដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈម្តងរួចមកហើយ ហើយជាតម្រូវការចាំបាច់បន្ទាន់ និងមិនមានពេលគ្រប់គ្រាន់សម្រាប់ធ្វើការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី ២
- ការដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈលើកទី ២ មិនទទួលបានជោគជ័យ
- តម្រូវការចាំបាច់បន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះអាសន្នផ្សេងទៀត ហើយមានរយៈពេលខ្លីមិនអាចរង់ចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន ឬ
- សម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ដកបទពិសោធន៍ ឬ អភិវឌ្ឍន៍ ។

ខ. **ការបន្តចុះកិច្ចសន្យា:** ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឱ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ ឬអ្នកផ្តល់សេវាកម្ម ក្នុងកាលៈទេសៈ:

- មុខសញ្ញាលទ្ធកម្មដូចគ្នានឹងមុខសញ្ញាលទ្ធកម្មក្នុងកិច្ចសន្យាដើម ដែលទទួលបានតាមរយៈការដេញថ្លៃ
- ស្ថិតក្នុងអំឡុងពេលមិនលើសពី ០៦ខែ បន្ទាប់កិច្ចសន្យាដើមចូលជាធរមាន និងស្ថិតក្នុងឆ្នាំថវិកាតែមួយ
- តម្លៃឯកតាស្មើ ឬទាបជាងតម្លៃឯកតាក្នុងកិច្ចសន្យាដើម និង
- មានតម្លៃសរុបមិនលើសពី ២៥ ភាគរយ នៃតម្លៃកិច្ចសន្យាដើម ។

គ. **ការចុះកិច្ចសន្យាជាមួយអង្គភាពជំនាញនៃស្ថាប័នរដ្ឋ:** ជាវិធីសាស្ត្រលទ្ធកម្មដែលតម្រូវឱ្យចរចាថ្លៃ និងបច្ចេកទេសផ្ទាល់ជាមួយអង្គភាពជំនាញរបស់ស្ថាប័នរដ្ឋ ដែលមានធនធាន គ្រឿងចក្រ ឧបករណ៍ សម្ភារៈ និង កំលាំងពលកម្ម គ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចសន្យា ។

ឃ. **ការចុះកិច្ចសន្យាជាមួយសហគមន៍** : ជាវិធីសាស្ត្រលទ្ធកម្មដែលត្រូវបានប្រើសំដៅលើកទឹកចិត្តដល់សហគមន៍ក្នុងស្រុក ដើម្បីប្រើប្រាស់កំលាំងពលកម្ម ចំណេះដឹង និងសម្ភារៈក្នុងស្រុកសម្រាប់ចូលរួមអភិវឌ្ឍន៍សហគមន៍ ។

# ជំពូកទី ៥
# លទ្ធកម្មសេវាទីប្រឹក្សា

## មាត្រា ១៥._

ទីប្រឹក្សាអាចត្រូវបានជ្រើសរើសដើម្បីផ្តល់នូវសេវាឯកទេសសម្រាប់គ្រប់គ្រងគម្រោង អនុវត្តកិច្ចសន្យាសំខាន់ៗ ឬ ផ្តល់យោបល់ជំនាញក្នុងការងារពង្រឹងពង្រីកស្ថាប័ន ឬ បង្កើនសមត្ថភាព ។ ទីប្រឹក្សាអាចជាក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សាឯកត្តជន ។

## មាត្រា ១៦._

ក្រុមហ៊ុនទីប្រឹក្សា ត្រូវបានជ្រើសរើសនៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ ។ ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវផ្អែកលើសំណើបច្ចេកទេស និងសំណើហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទីប្រឹក្សានីមួយៗ ។

**មាត្រា ១៧.-**

ទីប្រឹក្សាឯកត្តជន ត្រូវបានជ្រើសរើសដោយផ្អែកលើលក្ខណសម្បត្តិរបស់ទីប្រឹក្សាសម្រាប់ផ្តល់សេវាជូនស្ថាប័នអនុវត្តលទ្ធកម្ម ។ លក្ខណសម្បត្តិរបស់ទីប្រឹក្សាឯកត្តជន រួមមានចំណេះដឹង កម្រិតជំនាញវិជ្ជាជីវៈ បទពិសោធនិងកម្រិតជំនាញពាក់ព័ន្ធដទៃទៀតរបស់ទីប្រឹក្សាម្នាក់ៗ ។

**មាត្រា ១៨.-**

វិធីសាស្ត្រជ្រើសរើសទីប្រឹក្សារួមមាន ការជ្រើសរើសផ្អែកលើគុណភាព ការជ្រើសរើសផ្អែកលើគុណភាពនិងតម្លៃ ការជ្រើសរើសផ្អែកលើថវិកាកំណត់ ការជ្រើសរើសផ្អែកលើតម្លៃទាបបំផុត ការជ្រើសរើសផ្អែកលើការចរចាផ្ទាល់ និងការជ្រើសរើសផ្អែកលើលក្ខណសម្បត្តិ ។

**មាត្រា ១៩.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាព ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ។ វិធីសាស្ត្រនេះត្រូវបានអនុវត្តនៅពេលស្ថាប័នអនុវត្តលទ្ធកម្ម មានតម្រូវការសេវាទីប្រឹក្សាច្រើនដែលមានការពាក់ព័ន្ធគ្នាក្នុងពេលតែមួយ និងផ្តោតជាសំខាន់ទៅលើកម្រិតបច្ចេកទេសនៃសេវាទាំងនោះ ។

**មាត្រា ២០.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើគុណភាពនិងតម្លៃ ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សានៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានការថ្លឹងថ្លែងអំពីគុណភាព និងតម្លៃស្របទៅតាមកម្រិតបច្ចេកទេសស្មុគស្មាញនៃសេវាដែលត្រូវការ ។

**មាត្រា ២១.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើថវិកាកំណត់ ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា នៅពេលដែលស្ថាប័នអនុវត្តលទ្ធកម្មមានថវិកាក្នុងកម្រិតមួយកំណត់ និងទិសដៅច្បាស់លាស់ ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវបញ្ជាក់ឱ្យបានច្បាស់ពីចំនួនថវិកាដែលមាន ដើម្បីឱ្យក្រុមហ៊ុនទីប្រឹក្សាដាក់សំណើបច្ចេកទេសតម្រូវតាមចំនួនថវិកានោះ ។

**មាត្រា ២២.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើតម្លៃទាបបំផុត ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ។ វិធីសាស្ត្រនេះត្រូវបានអនុវត្តនៅពេលស្ថាប័នអនុវត្តលទ្ធកម្មមានតម្រូវការសេវាទីប្រឹក្សាដែលមានលក្ខណៈបទដ្ឋាន និងមានការរៀបចំបានល្អ ។

**មាត្រា ២៣.-**

វិធីសាស្ត្រជ្រើសរើសផ្អែកលើការចរចាផ្ទាល់ត្រូវបានប្រើសម្រាប់ជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សាឯកត្តជន នៅក្នុងកាលៈទេសៈពិសេស ។ កាលៈទេសៈពិសេសដែលសមស្របនឹងវិធីសាស្ត្រនេះរួមមានៈ

- ការងារបន្តពីមុនដែលបានអនុវត្តដោយក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជន
- ក្នុងករណីបន្ទាន់បំផុតដែលតម្រូវឱ្យមានការឆ្លើយតបភ្លាមៗ ឬ
- ក្នុងករណីមានតែក្រុមហ៊ុនមួយ ឬ ទីប្រឹក្សាម្នាក់ប៉ុណ្ណោះដែលមានសមត្ថភាព និងបទពិសោធ ។

**មាត្រា ២៤.–**

វិធីសាស្ត្រជ្រើសរើសផ្អែកលើលក្ខណសម្បត្តិ ត្រូវបានប្រើសម្រាប់ជ្រើសរើសទីប្រឹក្សាឯកត្តជន ។ ការជ្រើសរើសតាមវិធីសាស្ត្រនេះត្រូវផ្អែកលើចំណេះដឹង កម្រិតជំនាញវិជ្ជាជីវៈ បទពិសោធ និងកម្រិតជំនាញពាក់ព័ន្ធផ្សេងទៀតរបស់ទីប្រឹក្សា។

**មាត្រា ២៥.–**

ការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីបើកទូលាយអោយក្រុមហ៊ុនទីប្រឹក្សាក្នុងស្រុក និងអន្តរជាតិចូលរួមដាក់សំណើបញ្ជាក់ពីចំណាប់អារម្មណ៍ ។ ការផ្សព្វផ្សាយជ្រើសរើសក្រុមហ៊ុនទីប្រឹក្សាត្រូវធ្វើឡើងជាភាសាខ្មែរ និងបរទេស ។

ការជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណសម្បត្តិនៃជំនាញ បទពិសោធ និង សមត្ថភាពរបស់ឯកត្តជន ។ ការផ្សព្វផ្សាយជ្រើសរើសទីប្រឹក្សាឯកត្តជន ត្រូវធ្វើឡើងជាសាធារណៈដើម្បីបើកទូលាយអោយទីប្រឹក្សាឯកត្តជនក្នុងស្រុក និងទីប្រឹក្សាឯកត្តជនអន្តរជាតិចូលរួមដាក់សំណើបញ្ជាក់ពីចំណាប់អារម្មណ៍ ។ ការផ្សព្វផ្សាយជ្រើសរើសទីប្រឹក្សាឯកត្តជនត្រូវធ្វើឡើងជាភាសាខ្មែរ និងបរទេស ។

**មាត្រា ២៦.–**

នីតិវិធីនៃការជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា និង ទីប្រឹក្សាឯកត្តជន មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

## ជំពូកទី ៦

## លក្ខណសម្បត្តិអ្នកដេញថ្លៃ

**មាត្រា ២៧.–**

គ្រប់អ្នកដេញថ្លៃត្រូវបានផ្តល់ឱកាសដោយយុត្តិធម៌ និងស្មើភាពក្នុងការចូលរួមគ្រប់កិច្ចលទ្ធកម្មសាធារណៈដោយមិនប្រកាន់ពីសញ្ជាតិ ពូជសាសន៍ ភាសា សាសនា ភេទ ឬ អាយុ ទោះបីជាអ្នកដេញថ្លៃនោះធ្លាប់មាន ឬ កំពុងមានរឿងក្តីពាក់ព័ន្ធនឹងបណ្តឹងតវ៉ាលទ្ធកម្ម លើកលែងតែអ្នកដេញថ្លៃទាំងឡាយណាដែលស្ថិតក្នុងបញ្ជីខ្មៅ។

**មាត្រា ២៨.–**

អ្នកដេញថ្លៃត្រូវចុះបញ្ជីចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់

អ្នកដេញថ្លៃតាមកម្រិតសមត្ថភាពរបស់អ្នកដេញថ្លៃដើម្បីធានាអនុវត្តកិច្ចសន្យា។ នីតិវិធីនៃការធ្វើចំណាត់ប្រភេទ និង ចំណាត់ថ្នាក់អ្នកដេញថ្លៃមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ២៩.–**

ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តលទ្ធកម្មសម្រាប់តែគម្រោងដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ។ នីតិវិធីសម្រាប់ធ្វើបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ មានកំណត់ក្នុងវិធាន និង បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៣០.–**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវកំណត់លក្ខណសម្បត្តិតាមក្រោយចំពោះអ្នកដេញថ្លៃជោគជ័យ មុនការសម្រេចប្រគល់កិច្ចសន្យា។ នីតិវិធីសម្រាប់កំណត់លក្ខណសម្បត្តិតាមក្រោយមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៣១.–**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចុះឈ្មោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការក្នុងបញ្ជីខ្មៅបន្ទាប់ពីបានរកឃើញថា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់នេះ ឬ មានពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត អំពើបង្ខិតបង្ខំ ឬ ផ្តល់ភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្ម ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវជម្រះចេញពីបញ្ជីខ្មៅចំពោះអ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការដែលផុតសុពលភាពក្នុងបញ្ជីខ្មៅ ។

ការចុះ និងការជម្រះបញ្ជីខ្មៅត្រូវផ្សព្វផ្សាយជាសាធារណៈ និងត្រូវចម្លងជូនគ្រប់ស្ថាប័នអនុវត្តលទ្ធកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ។

នីតិវិធីនៃការចុះ ការជម្រះ និង ការផ្សព្វផ្សាយបញ្ជីខ្មៅ មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

## ជំពូកទី ៧

## ផែនការលទ្ធកម្ម

**មាត្រា ៣២.–**

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ។ ផែនការលទ្ធកម្មត្រូវមានសង្គតិភាពជាមួយកញ្ចប់ថវិកាប្រចាំឆ្នាំ ។ ផែនការលទ្ធកម្មត្រូវកត់ត្រាឱ្យបានច្បាស់លាស់អំពីប្រភេទលទ្ធកម្ម ឈ្មោះគម្រោង តម្លៃប៉ាន់ស្មានគម្រោង វិធីសាស្ត្រលទ្ធកម្ម កាលវិភាគសម្រាប់អនុវត្តដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្ម និងកាលវិភាគសម្រាប់ទូទាត់ ។

រាល់គម្រោងចំណាយដែលត្រូវអនុវត្តកិច្ចលទ្ធកម្មត្រូវកត់ត្រាបញ្ចូលក្នុងផែនការលទ្ធកម្ម។ ករណីមិនមានកត់ត្រាក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតឱ្យផ្តល់ចំណាយឡើយ។

នីតិវិធីនៃការរៀបចំផែនការលទ្ធកម្មមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

**មាត្រា ៣៣.-**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចងជាកញ្ចប់លទ្ធកម្ម ចំពោះមុខសញ្ញាលទ្ធកម្មដែលស្ថិតក្នុងប្រភេទដូចគ្នា មានលក្ខណៈដូចគ្នា ឬ ប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែង សម្រាប់ធ្វើកិច្ចលទ្ធកម្មតែមួយលើកដើម្បីបង្កើនកម្រិតគុណភាពនៃការប្រកួតប្រជែង សន្សំសំចៃសោហ៊ុយចំណាយ និងចំណេញពេលវេលា។

**មាត្រា ៣៤.-**

ហាមបំបែកគម្រោងទៅជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ឬតម្រូវតាមសិទ្ធិសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម។

**មាត្រា ៣៥.-**

ផែនការលទ្ធកម្មត្រូវបានអនុញ្ញាតឱ្យធ្វើការកែតម្រូវក្នុងករណីចាំបាច់។ រាល់ការកែតម្រូវផែនការលទ្ធកម្មដែលមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្ម ឬ ដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវបានហាមឃាត់។

**មាត្រា ៣៦.-**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែ ធ្នូ មុនឆ្នាំអនុវត្តថវិកា។

**មាត្រា ៣៧.-**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវអនុវត្តឱ្យបានហ្មឹងមាត់តាមផែនការលទ្ធកម្មប្រចាំឆ្នាំ ដែលបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើរបាយការណ៍លទ្ធកម្មជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានទៀងទាត់។

## ជំពូកទី ៨
## នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្ម

**មាត្រា ៣៨.-**

អង្គភាពលទ្ធកម្មត្រូវអនុវត្តកិច្ចលទ្ធកម្មឱ្យបានស្របទៅតាមផែនការលទ្ធកម្ម និងឯកសារដេញថ្លៃដែលបានផ្តល់ទិដ្ឋាការយល់ព្រមរួច។

**មាត្រា ៣៩.-**

អង្គភាពលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃសម្រាប់ធ្វើការផ្សព្វផ្សាយ ដើម្បីជ្រើសរើសអ្នកដេញថ្លៃ ។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃត្រូវមានព័ត៌មានសំខាន់ៗ ដូចខាងក្រោម :

- ការពណ៌នាលម្អិតអំពីប្រភេទ និងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្មដែលត្រូវធ្វើលទ្ធកម្ម
- ឈ្មោះ អាសយដ្ឋាន អ៊ីម៉ែល និង ទូរសាររបស់អង្គភាពលទ្ធកម្ម
- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត
- លក្ខខណ្ឌតម្រូវនានានៃលក្ខណសម្បត្តិ ឬបុរេលក្ខណសម្បត្តិ
- កាលបរិច្ឆេទទទួលនិងបើកឯកសារដេញថ្លៃ ឬ ឯកសារកំណត់បុរេលក្ខណសម្បត្តិ
- ការបញ្ជាក់អំពីលក្ខខណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។

**មាត្រា ៤០.-**

អង្គភាពលទ្ធកម្មត្រូវរៀបចំឯកសារដេញថ្លៃអោយស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះដោយបញ្ជាក់ពីលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឱ្យបានច្បាស់លាស់ សម្រាប់ដាក់ជូនប្រធានស្ថាប័នអនុវត្តលទ្ធកម្មពិនិត្យ និងចុះហត្ថលេខា ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវស្នើសុំទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែឯកសារដេញថ្លៃនៃកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្ទង់តម្លៃ ។ បទដ្ឋាននៃឯកសារដេញថ្លៃមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៤១.-**

សេចក្តីជូនដំណឹងស្តីពីបុរេលក្ខណសម្បត្តិ ការដេញថ្លៃ និងសេចក្តីកែសម្រួលនានាត្រូវប្រកាសផ្សព្វផ្សាយតាមគេហទំព័រលទ្ធកម្មសាធារណៈ តាមសារព័ត៌មានជាតិ-អន្តរជាតិ ហើយត្រូវបិទផ្សាយនៅលើបញ្ជរព័ត៌មានរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

**មាត្រា ៤២.-**

ឯកសារដេញថ្លៃត្រូវផ្សព្វផ្សាយលើគេហទំព័រលទ្ធកម្មសាធារណៈ ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវរៀបចំឯកសារដេញថ្លៃឱ្យបានគ្រប់គ្រាន់សម្រាប់លក់ជូនអ្នកដែលមានបំណងចូលរួមដេញថ្លៃ ។ តម្លៃលក់ឯកសារដេញថ្លៃ ត្រូវប្រហាក់ប្រហែលនឹងតម្លៃដើមនៃការរៀបចំឯកសារដេញថ្លៃនោះ ។ ការលក់ឯកសារដេញថ្លៃត្រូវបានបញ្ឈប់ ២៤ម៉ោង មុនកាលបរិច្ឆេទកំណត់ឈប់ទទួលសំណើដេញថ្លៃ ។

**មាត្រា ៤៣.-**

ប្រសិនបើមានការស្នើសុំបំភ្លឺជាលាយលក្ខណ៍អក្សរពីអ្នកដេញថ្លៃណាមួយអំពីឯកសារដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅគ្រប់អ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃ ។ ក្នុងករណីចាំបាច់

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើការប្រជុំមុនការដេញថ្លៃ ដើម្បីធ្វើការឆ្លើយបំភ្លឺ ដោយអញ្ជើញអ្នកដេញថ្លៃដែលបានទទួលឯកសារដេញថ្លៃចូលរួម ។

**មាត្រា ៤៤.-**

អង្គភាពលទ្ធកម្មត្រូវទទួល ចុះបញ្ជី និងរៀបចំរក្សាទុកសំណើដេញថ្លៃដែលដាក់ក្នុងស្រោមសំបុត្របិទភ្ជិតនៅកន្លែងមានសុវត្ថិភាព ដោយមិនត្រូវប៉ះពាល់ឱ្យខូចទម្រង់ដើមនៃស្រោមសំបុត្រដាក់សំណើដេញថ្លៃនោះទេមុនកាលបរិច្ឆេទបើកសំណើដេញថ្លៃ ។ រាល់សំណើដេញថ្លៃត្រូវភ្ជាប់មកជាមួយនូវលិខិតប្រាក់កក់ធានាការដេញថ្លៃ លើកលែងតែសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្ទង់តម្លៃ ។ កម្រិតនៃចំនួនប្រាក់កក់ធានាការដេញថ្លៃមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៤៥.-**

សំណើដេញថ្លៃទាំងអស់ត្រូវបើកជាសាធារណៈភ្លាមៗ បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ ។ ព័ត៌មានសំខាន់ៗនៃសំណើដេញថ្លៃនីមួយៗត្រូវប្រកាសនៅចំពោះមុខអ្នកចូលរួមបើកសំណើដេញថ្លៃ និងត្រូវកត់ត្រាក្នុងកំណត់ហេតុបើកឯកសារដេញថ្លៃ រួចចម្លងជូនគ្រប់អ្នកដេញថ្លៃ និងអ្នកចូលរួមបើកសំណើដេញថ្លៃទាំងអស់ ។

ប្រសិនបើក្នុងដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មមិនត្រូវបើកសំណើដេញថ្លៃទាំងនោះឡើយ ហើយសំណើដេញថ្លៃត្រូវបញ្ជូនត្រឡប់ទៅឱ្យអ្នកដេញថ្លៃវិញ ។

ក្នុងករណីដំណើរការដេញថ្លៃលើកដំបូងទទួលបានសំណើដេញថ្លៃតិចជាងបី គ្មានទទួលបានសំណើដេញថ្លៃ ឬពុំមានការឆ្លើយតបនឹងការដេញថ្លៃ នោះត្រូវដំណើរការដេញថ្លៃឡើងវិញ ។

ក្នុងដំណើរការដេញថ្លៃឡើងវិញ ទោះបីទទួលបានសំណើដេញថ្លៃចំនួនប៉ុន្មាន ក៏ត្រូវតែដំណើរការបើកសំណើដេញថ្លៃទាំងនោះ តាមកាលបរិច្ឆេទកំណត់ ។

**មាត្រា ៤៦.-**

គណៈកម្មាធិការលទ្ធកម្ម ត្រូវធ្វើការពិនិត្យវាយតម្លៃលើសំណើដេញថ្លៃទាំងអស់ជាសម្ងាត់ ។ លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងឯកសារដេញថ្លៃ ព័ត៌មានប្តឹងជំទាស់ និងកំណត់ហេតុបើកសំណើដេញថ្លៃ គឺជាមូលដ្ឋានសម្រាប់វាយតម្លៃប្រគល់កិច្ចសន្យា ។ លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនមានចែងក្នុងឯកសារដេញថ្លៃមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការវាយតម្លៃឡើយ ។ នីតិវិធីវាយតម្លៃសំណើដេញថ្លៃ មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៤៧.-**

មុននឹងចាប់ផ្តើមត្រួតពិនិត្យ និងវាយតម្លៃលើសំណើដេញថ្លៃនៃកិច្ចលទ្ធកម្មនីមួយៗ សមាជិកគណៈកម្មាធិការលទ្ធកម្មដែលត្រូវចូលរួមវាយតម្លៃប្រគល់កិច្ចសន្យា ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈដូចមានចែងក្នុងជំពូក ១១ នៃច្បាប់នេះ ។

**មាត្រា ៤៨.–**

បន្ទាប់ពីបញ្ចប់ការវាយតម្លៃសំណើដេញថ្លៃ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកដេញថ្លៃឈ្នះ ដោយចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់។ ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យឡើងវិញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យាត្រូវធ្វើឡើងក្រោយពេលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៤៩.–**

ប្រសិនបើមិនមានការជំទាស់តវ៉ាណាមួយក្នុងរយៈពេល ១០ថ្ងៃការងារ បន្ទាប់ពីការចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា អង្គភាពលទ្ធកម្មត្រូវស្នើឱ្យអ្នកដេញថ្លៃឈ្នះផ្តល់នូវលិខិតប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា និងត្រូវរៀបចំកិច្ចសន្យាលទ្ធកម្ម ដូចមានចែងក្នុងជំពូក ៩ នៃច្បាប់នេះ ។

**មាត្រា ៥០.–**

ការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្មត្រូវធ្វើឡើងរវាងប្រធានស្ថាប័នអនុវត្តលទ្ធកម្ម និងអ្នកដេញថ្លៃឈ្នះ។ ក្នុងករណីកិច្ចលទ្ធកម្មដែលត្រូវពិនិត្យឡើងវិញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កិច្ចសន្យាលទ្ធកម្មត្រូវមានការចុះហត្ថលេខាបញ្ជាក់យល់ព្រមបន្ថែមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា ៥១.–**

ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់ចែងគ្រប់គ្រងកិច្ចសន្យាឱ្យបានហ្មឹងម៉ាត់ ដើម្បីធានាឱ្យការអនុវត្តកិច្ចសន្យាប្រព្រឹត្តទៅបានត្រឹមត្រូវស្របតាមលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យា។

**មាត្រា ៥២.–**

លទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច ត្រូវធ្វើឡើងតាមរយៈប្រព័ន្ធអ៊ិនធើណែត នៅពេលដែលប្រព័ន្ធព័ត៌មានវិទ្យាក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រើប្រាស់ទូលំទូលាយ និងមានភាពរឹងមាំ។ នីតិវិធីនៃការអនុវត្តកិច្ចលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិច មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

**មាត្រា ៥៣.–**

កិច្ចលទ្ធកម្មសាធារណៈជាកម្មវត្ថុនៃការធ្វើសវនកម្ម និងអធិការកិច្ច ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងច្បាប់ពាក់ព័ន្ធដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី ៩

## កិច្ចសន្យាលទ្ធកម្ម

**មាត្រា ៥៤.-**

ការរៀបចំកិច្ចសន្យាត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ បទប្បញ្ញត្តិនៃច្បាប់ដទៃទៀតដែលអាចយកមកអនុវត្តបាន និងស្របតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារដេញថ្លៃ ព្រមទាំងត្រូវអនុលោមតាមមាតិកាដូចមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៥៥.-**

កិច្ចសន្យាលទ្ធកម្មត្រូវចែងជាភាសាខ្មែរ ។ ករណីចាំបាច់ កិច្ចសន្យាអាចសរសេរជាភាសាបរទេសដោយត្រូវបកប្រែចេញពីកិច្ចសន្យាជាភាសាខ្មែរ ។ ក្នុងករណីមានខ្លឹមសារមិនស្របគ្នារវាងភាសាខ្មែរ និងភាសាបរទេស កិច្ចសន្យាជាភាសាខ្មែរជាឯកសារផ្លូវការ ។

**មាត្រា ៥៦.-**

គ្រប់កិច្ចសន្យាលទ្ធកម្មត្រូវទូទាត់ជាប្រាក់រៀល លើកលែងតែចំពោះកិច្ចសន្យាសម្រាប់អនុវត្តគម្រោងលទ្ធកម្មនៅក្រៅប្រទេស ដែលអាចអនុញ្ញាតឱ្យទូទាត់ជារូបិយប័ណ្ណបរទេស ។

**មាត្រា ៥៧.-**

លក្ខណៈបច្ចេកទេស ទំនិញ សំណង់ សេវាកម្ម ដែលចែងក្នុងកិច្ចសន្យា ត្រូវដូចគ្នានឹងលក្ខណៈបច្ចេកទេសដែលមានចែងក្នុងឯកសារដេញថ្លៃ ។

**មាត្រា ៥៨.-**

តម្លៃកិច្ចសន្យាមិនត្រូវលើសពីតម្លៃដេញឈ្នះក្រោយការកែតម្រូវលេខគណិត ។ តម្លៃកិច្ចសន្យាជាតម្លៃថេរក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា លើកលែងតែក្នុងកាលៈទេសៈពិសេសខ្លះតម្លៃកិច្ចសន្យាអាចកែប្រែបាន ប៉ុន្តែត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិន ។ កាលៈទេសៈពិសេស ដែលអាចកែប្រែតម្លៃកិច្ចសន្យាមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៥៩.-**

រាល់កិច្ចសន្យាត្រូវមានប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា លើកលែងតែកិច្ចសន្យាដែលទទួលបានតាមរយៈវិធីសាស្រ្តលទ្ធកម្មស្ទង់តម្លៃ កិច្ចសន្យាជាមួយទីប្រឹក្សាឯកត្តជន និង កិច្ចសន្យាជាមួយអង្គភាពរដ្ឋ ។ អ្នកដេញថ្លៃឈ្នះត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាមុនពេលកិច្ចសន្យាចូលជាធរមាន ។ ចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវស្មើចំនួនដែលបានចែងក្នុងឯកសារដេញថ្លៃ ។ សមាមាត្រនៃចំនួនប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាត្រូវរឹបអូសបង់ចូលថវិការដ្ឋ ប្រសិនអ្នកដេញថ្លៃឈ្នះបដិសេធអនុវត្ត កិច្ចសន្យាដែលបានចូលជាធរមាន ឬបំពានលក្ខខណ្ឌកិច្ចសន្យាហើយត្រូវស្ថាប័នអនុវត្តលទ្ធកម្មបញ្ឈប់កិច្ចសន្យាមុន កាលកំណត់ ។ ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា មានសុពលភាពរហូតដល់ចប់រយៈពេលធានាគុណភាពសំណង់ ទំនិញ ឬសេវាកម្ម ។

**មាត្រា ៦០._**

រាល់ការកែប្រែឯកសារកិច្ចសន្យាត្រូវធ្វើឡើងដោយការព្រមព្រៀង និងអនុម័តយល់ព្រមពីគ្រប់ភាគីហត្ថលេខី នៃកិច្ចសន្យា ។

**មាត្រា ៦១._**

ការប្រគល់-ទទួលត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវតាមទំហំ បរិមាណ គុណភាព លក្ខណៈបច្ចេកទេស និងស្រប តាមពេលវេលាដែលបានកំណត់ក្នុងកាលវិភាគប្រគល់-ទទួលដូចមានចែងក្នុងកិច្ចសន្យា និងត្រូវស្ថិតក្រោមការត្រួត ពិនិត្យរបស់គណៈកម្មការប្រគល់-ទទួល ។

**មាត្រា ៦២._**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវរៀបចំការទូទាត់តម្លៃកិច្ចសន្យាជូនអ្នកផ្គត់ផ្គង់ ឬ អ្នកទទួលការ ដោយផ្អែកលើ លក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា ។

**មាត្រា ៦៣._**

អ្នកដេញថ្លៃឈ្នះអាចចុះកិច្ចសន្យាបន្តនូវផ្នែកខ្លះនៃគម្រោងទៅអោយភាគីទីបី ប៉ុន្តែត្រូវមានការយល់ព្រម ជាលាយលក្ខណ៍អក្សរជាមុនពីស្ថាប័នអនុវត្តលទ្ធកម្ម ។ ករណីកិច្ចសន្យាលទ្ធកម្មដែលត្រូវពិនិត្យឡើងវិញដោយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំការយល់ព្រមបន្ថែមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ករណីអ្នកដេញថ្លៃឈ្នះត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាបន្តជាមួយភាគីទីបី អ្នកដេញថ្លៃឈ្នះត្រូវទទួលខុស ត្រូវចំពោះមុខស្ថាប័នអនុវត្តលទ្ធកម្មលើការអនុវត្តគម្រោងទាំងមូល ។

**មាត្រា ៦៤._**

គ្មានភាគីណាមួយមានសិទ្ធិបញ្ចប់កិច្ចសន្យាដោយឯកតោភាគីបានឡើយ លើកលែងតែមានការរំលោភបំពាន ពីភាគីម្ខាងទៀត ។ លក្ខខណ្ឌលម្អិត និងនីតិវិធីនៃការបញ្ចប់កិច្ចសន្យា មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្ម សាធារណៈ ។

# ជំពូកទី ១០
## ការដោះស្រាយជម្លោះ និង បណ្តឹងតវ៉ា

### មាត្រា ៦៥._

ពេលពិនិត្យឃើញថាមានភាពមិនប្រក្រតីក្នុងដំណើរការលទ្ធកម្ម អ្នកដេញថ្លៃមានសិទ្ធិដាក់ពាក្យប្តឹងតវ៉ាទៅសាមីស្ថាប័នអនុវត្តលទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត ដូចមានចែងក្នុងមាត្រា៦៦ មាត្រា៦៨ និងមាត្រា៧០ នៃច្បាប់នេះ ។ ពាក្យប្តឹងតវ៉ាត្រូវភ្ជាប់មកជាមួយនូវព័ត៌មាន ឬឯកសារភស្តុតាងគ្រប់គ្រាន់ និងមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានត្រឹមត្រូវរបស់អ្នកប្តឹងតវ៉ា ។

### មាត្រា ៦៦._

អ្នកដេញថ្លៃអាចដាក់ពាក្យប្តឹងតវ៉ានៅសាមីស្ថាប័នអនុវត្តលទ្ធកម្មភ្លាមៗ ឬក្នុងរយៈពេល ០៥ ថ្ងៃការងារបន្ទាប់ពីដំណាក់កាលលទ្ធកម្មនីមួយៗត្រូវបានបញ្ចប់ លើកលែងតែការប្តឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការជ្រើសរើសអ្នកដេញថ្លៃដែលអនុញ្ញាតឱ្យដាក់ពាក្យប្តឹងតវ៉ាក្នុងរយៈពេល ១០ ថ្ងៃការងារ បន្ទាប់ពីកាលបរិច្ឆេទនៃការប្រកាសលទ្ធផលនៃការដេញថ្លៃ ។ ពាក្យប្តឹងតវ៉ាលទ្ធកម្មដែលដាក់ ឬ ផ្ញើមកដល់ស្ថាប័នអនុវត្តលទ្ធកម្មក្រោយកាលកំណត់នេះពុំមានសុពលភាពឡើយ ។ អ្នកប្តឹងតវ៉ាត្រូវថតចម្លងពាក្យប្តឹងតវ៉ារបស់ខ្លួនជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយច្បាប់ ។

ការប្តឹងតវ៉ានៅស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវដោះស្រាយដោយគណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ។ នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ដែលត្រូវអនុវត្តដោយគណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មមានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

### មាត្រា ៦៧._

គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើការពិនិត្យពាក្យប្តឹងតវ៉ា និងផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ ថ្ងៃការងារ គិតពីថ្ងៃទទួលពាក្យប្តឹងតវ៉ា លើកលែងតែចំពោះពាក្យប្តឹងតវ៉ាដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃប្រគល់កិច្ចសន្យាត្រូវឆ្លើយតបភ្លាមៗបន្ទាប់ពីការប្រកាសប្រគល់កិច្ចសន្យារួច ។ ស្ថាប័នអនុវត្តលទ្ធកម្មត្រូវថតចម្លងលិខិតឆ្លើយតបទៅអ្នកប្តឹងតវ៉ាជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយច្បាប់ ។

### មាត្រា ៦៨._

ប្រសិនបើអ្នកប្តឹងតវ៉ាមិនពេញចិត្តនឹងចម្លើយរបស់គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម ឬ គណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មពុំបានផ្តល់ចម្លើយក្នុងរយៈពេលដូចបានកំណត់ក្នុងមាត្រា៦៦ នៃច្បាប់នេះ អ្នកប្តឹងតវ៉ាមានសិទ្ធិប្តឹងបន្តទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេល ១០ ថ្ងៃការងារ គិតពីថ្ងៃដែលគណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មបានផ្តល់ចម្លើយ ឬថ្ងៃចុងក្រោយដែលគណៈកម្មាធិការលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្តល់ចម្លើយ ។

នីតិវិធីនៃការដោះស្រាយជម្លោះ និងបណ្តឹងតវ៉ាលទ្ធកម្ម ដែលត្រូវអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ។

**មាត្រា ៦៩._**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការពិនិត្យដោះស្រាយពាក្យប្តឹងតវ៉ា និងត្រូវផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរ ឬចេញសេចក្តីសម្រេចក្នុងរយៈពេល ១០ ថ្ងៃការងារ គិតពីថ្ងៃទទួលពាក្យប្តឹងតវ៉ា ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវជូនដំណឹងដល់ស្ថាប័នអនុវត្តលទ្ធកម្មអំពីចម្លើយ ឬសេចក្តីសម្រេចនោះ។

**មាត្រា ៧០._**

សេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការដោះស្រាយជម្លោះ និងបណ្តឹងតវ៉ាលទ្ធកម្ម ជាសេចក្តីសម្រេចចុងក្រោយ ។ ប៉ុន្តែប្រសិនបើអ្នកប្តឹងតវ៉ានៅតែមិនពេញចិត្តចំពោះសេចក្តីសម្រេចនោះ អ្នកប្តឹងតវ៉ាមានសិទ្ធិប្តឹងតវ៉ាទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ១០ ថ្ងៃការងារ គិតពីថ្ងៃចេញសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៧១._**

ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវបន្តដំណើរការនៃកិច្ចលទ្ធកម្មដោយមិនចាំបាច់រង់ចាំសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តុលាការឡើយ ។

**មាត្រា ៧២._**

ក្នុងករណីរកឃើញថា អ្នកប្តឹងតវ៉ាមានគោលបំណងរំខានដើម្បីធ្វើឱ្យមានការកែប្រែ ឬ ពន្យារពេលនៃដំណើរការលទ្ធកម្ម ដោយបានដាក់ពាក្យប្តឹងតវ៉ាពុំមានមូលដ្ឋានព័ត៌មានច្បាស់លាស់ ឬ បានភ្ជាប់ឯកសារភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវ អ្នកប្តឹងតវ៉ាត្រូវប្រឈមនឹងទោសទណ្ឌដូចមានចែងក្នុងមាត្រា៧៧ នៃច្បាប់នេះ ។

## ជំពូកទី ១១
## ក្រមសីលធម៌វិជ្ជាជីវៈ

**មាត្រា ៧៣._**

គ្រប់សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម គ្រប់មន្ត្រីលទ្ធកម្ម អ្នកដេញថ្លៃ ព្រមទាំងមន្ត្រី និងបុគ្គលដទៃទៀតដែលមានការពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងពេលដំណើរការលទ្ធកម្មសាធារណៈ ដោយត្រូវចៀសវាងដាច់ខាតការប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃច្បាប់នេះ អនុក្រឹត្យ វិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងមិនត្រូវពាក់ព័ន្ធជាមួយនឹងទំនាស់ផលប្រយោជន៍ អំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬ អំពើបង្ខិតបង្ខំ ។

**មាត្រា ៧៤.**_

គ្រប់សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម គ្រប់មន្ត្រីអង្គភាពលទ្ធកម្ម និងអ្នកដេញថ្លៃ ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ ។ មន្ត្រីលទ្ធកម្មត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសនេះរៀងរាល់ឆ្នាំ ។ សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសនេះរៀងរាល់ពេលពិនិត្យវាយតម្លៃប្រគល់កិច្ចសន្យា។ ដោយឡែកអ្នកដេញថ្លៃត្រូវចុះហត្ថលេខាលើសេចក្តីប្រកាសនេះរៀងរាល់ពេលដាក់ពាក្យសុំដេញថ្លៃ ។

**មាត្រា ៧៥.**_

ប្រសិនបើមានភស្តុតាងបញ្ជាក់ថា សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម មន្ត្រីលទ្ធកម្ម អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ មានជាប់ពាក់ព័ន្ធនឹងអំពើប្រាសចាកក្រមសីលធម៌វិជ្ជាជីវៈ ត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា៧៦ និងមាត្រា៧៧ នៃច្បាប់នេះ ។

## ជំពូកទី ១២
## ទោសប្បញ្ញត្តិ

**មាត្រា ៧៦.**_

មន្ត្រីសាធារណៈគ្រប់លំដាប់ថ្នាក់ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬត្រូវបានរកឃើញថាមានពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំ នៅក្នុងដំណើរការលទ្ធកម្មត្រូវទទួលទណ្ឌកម្មផ្នែករដ្ឋបាល។ ទណ្ឌកម្មផ្នែករដ្ឋបាលនេះមិនមែនជាឧបសគ្គដល់ដំណើរការនៃការចោទប្រកាន់ និងផ្តន្ទាទោសដោយយោងតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៧៧.**_

អ្នកដេញថ្លៃ អ្នកទទួលការ ឬអ្នកផ្គត់ផ្គង់ ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬត្រូវបានរកឃើញថា មានពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត អំពើបង្ខិតបង្ខំ ឬ ផ្តល់ភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវក្នុងពេលដាក់ពាក្យប្តឹងតវ៉ានៅក្នុងដំណើរការលទ្ធកម្ម ត្រូវបណ្តេញចេញជាបន្ទាន់ពីក្នុងកិច្ចលទ្ធកម្មដែលកំពុងដំណើរការ ឬលុបកិច្ចសន្យាដែលកំពុងអនុវត្តភ្លាម១ និងត្រូវកត់ត្រាចូលក្នុងបញ្ជីខ្មៅ ដោយហាមឃាត់មិនឱ្យចូលរួមក្នុងគ្រប់កិច្ចលទ្ធកម្មសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬក្នុងរយៈពេលបីឆ្នាំយ៉ាងតិច ។ ការហាមឃាត់នេះមិនមែនជាឧបសគ្គដល់ដំណើរការនៃការចោទប្រកាន់ និងផ្តន្ទាទោសដោយយោងតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៧៨._**

អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះ ទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ វិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈដទៃទៀតដែលនៅជាធរមាន និងចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅមានសុពលភាពរហូតដល់មានអនុក្រឹត្យ វិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ១៤
## អវសានប្បញ្ញត្តិ

**មាត្រា ៧៩._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨០._**

ច្បាប់នេះត្រូវប្រកាសឱ្យអនុវត្តជាការប្រញាប់ ។